ថ្ងៃទី1 ខែ មេសា ឆ្នាំ2026

# ការប្រលងវាយតម្លៃពលករជំនាញកម្រិត1ក្នុងវិស័យ ផលិតចំណីអាហារ និងភេសជ្ជៈ សេចក្តីណែនាំអំពីការប្រលងនៅក្នុងប្រទេស

## 1. ស្តីអំពីការប្រលងវាយតម្លៃពលករជំនាញ កម្រិត1ក្នុងវិស័យផលិតចំណីអាហារ និងភេសជ្ជៈ

“ពលករជំនាញ”គឺជាប្រព័ន្ធដែលទទួលយកអ្នកដែលមានបច្ចេកទេសជំនាញនៅបរទេសអោយមកបំពេញការងារដែលខ្វះខាតមនុស្សធ្វើការនៅប្រទេសជប៉ុន ដូចជាវិស័យផលិតចំណីអាហារ និងភេសជ្ជៈជាដើម។

ដើម្បីទទួលបានសិទ្ធិស្នាក់នៅជាពលករជំនាញ កម្រិត1ក្នុងវិស័យផលិតចំណីអាហារ និងភេសជ្ជៈចាំបាច់ត្រូវប្រលងជាប់“ការប្រលងវាយតម្លៃពលករជំនាញកម្រិត1ក្នុងវិស័យផលិតចំណីអាហារ និងភេសជ្ជៈ” និង “ការប្រលងភាសាជប៉ុន” ទាំងពីរមុខ។

“ការប្រលងភាសាជប៉ុន” មាន “តេស្តមូលដ្ឋានគ្រឹះភាសាជប៉ុន (JFT-Basic)” ដែលរៀបចំដោយមូលនិធិជប៉ុន “ការប្រលងសមត្ថភាពជំនាញភាសាជប៉ុន (JLPT)” ដែលរៀបចំដោយមូលនិធិជប៉ុននិងសមាគមន៍គាំទ្រការអប់រំអន្តរជាតិជប៉ុន។

“ការប្រលងវាយតម្លៃពលករជំនាញកម្រិត1ក្នុងវិស័យផលិតចំណីអាហារ និងភេសជ្ជៈ” (ខាងក្រោម ហៅថា “ការប្រលង”) គឺត្រូវបានរៀបចំឡើងដោយស្ថាប័នវាយតម្លៃជំនាញបច្ចេកទេសឧស្សាហ៍កម្មម្ហូបអាហារសម្រាប់ជនបរទេស (OTAFF)

ប្រសិនបើចង់ដឹងអំពីការដាក់ពាក្យស្នើសុំសិទ្ធិស្នាក់នៅជាពលករជំនាញ សូមទាក់ទងសួរទៅកាន់ទីភ្នាក់ងារអន្តោប្រវេសន៍នៃក្រសួងយុត្តិធម៌ជប៉ុន។

ប្រសិនបើមានចម្ងល់អ្វីក្រៅពីការប្រលងវាយតម្លៃពលករជំនាញកម្រិត1ក្នុងវិស័យផលិតចំណីអាហារ និងភេសជ្ជៈ និងវិស័យភោជនីយដ្ឋានសូមសាកសួរពីក្នុង “សាកសួរព័ត៌មាន” ដែលមាននៅលើទំព័រដំបូងគេនៃគេហទំព័ររបស់ OTAFF។

## 2. លក្ខខណ្ឌនៃការទទួលការប្រលង

បុគ្គលដែលអាចទទួលការប្រលងវាយតម្លៃពលករជំនាញកម្រិត1ក្នុងវិស័យផលិតចំណីអាហារ និងភេសជ្ជៈ នៅក្នុងប្រទេសជប៉ុនបានគឺជាបុគ្គលដែលបំពេញតាមលក្ខខណ្ឌទាំង (1) និង (2) នៅថ្ងៃប្រលង។

(1) បុគ្គលដែលមានសិទ្ធស្នាក់នៅ (ចំណាំ1) និងមានអាយុចាប់ពី 17 ឆ្នាំពេញឡើងទៅគិតត្រឹមថ្ងៃប្រលង

(2) បុគ្គលដែលកាន់លិខិតឆ្លងដែន (ចំណាំ2) ដែលចេញដោយរដ្ឋាភិបាលបរទេស ឬស្ថាប័នមានសមត្ថកិច្ចក្នុងតំបន់ដែលប្រកាសកំណត់ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម្រាប់ជាកិច្ចសហការនៅក្នុងការអនុវត្តដីកាបង្គាប់ឱ្យនិរទេសដោយរលូន។

(ចំណាំ1) បុគ្គលដែលកំពុងស្នាក់នៅក្នុងប្រទេសជប៉ុនដោយគោរពតាមច្បាប់របស់ប្រទេសជប៉ុនគឺអាចទទួលការប្រលងបាន។ទោះបីមិនមានកាតស្នាក់នៅក៏ដោយប្រសិនបើជាបុគ្គលដែលស្នាក់នៅរយៈពេលខ្លីនៅប្រទេសជប៉ុនដោយគោរពតាមច្បាប់ក៏អាចទទួលការប្រលងបានដែរ។បុគ្គលដែលស្នាក់នៅប្រទេសជប៉ុនដោយមិនគោរពច្បាប់របស់ប្រទេសជប៉ុន (អ្នកស្នាក់នៅខុសច្បាប់) គឺមិនអាចទទួលការប្រលងបានឡើយ។

(ចំណាំ2) បច្ចុប្បន្ន បុគ្គលដែលកាន់លិខិតឆ្លងដែនក្រៅពីសាធារណៈរដ្ឋឥស្លាម អ៊ីរ៉ង់ គឺអាចទទួលការប្រលងបាន។

- ■ទោះបីជាជាប់ការប្រលងនេះក៏ដោយ ក៏មិនប្រាកដថាទទួលបានសិទ្ធិស្នាក់នៅជា "ពលករជំនាញ" បានដែរ។
- ■ទោះបីជាប្រលងជាប់ ហើយធ្វើការដាក់ពាក្យស្នើរសុំលិខិតបញ្ជាក់សិទ្ធិស្នាក់នៅ ឬពាក្យស្នើរសុំផ្លាស់ប្តូរសិទ្ធិស្នាក់នៅក៏ដោយក៏មិនប្រាកដថាអាចទទួលបានលិខិតបញ្ជាក់សិទ្ធិស្នាក់នៅបានដែរ។
- ■ទោះបីជាទទួលបានលិខិតបញ្ជាក់សិទ្ធិស្នាក់នៅក៏ដោយក៏មិនប្រាកដថាអាចទទួលបានវិសា (ទិដ្ឋាការ) ដែរ ពីព្រោះវិសា (ទិដ្ឋាការ) ក្រសួងការបរទេសនឹងធ្វើការត្រួតពិនិត្យដោយឡែកពីគ្នា។

**3. មុខវិជ្ជាប្រលង វិធីសាស្ត្រអនុវត្តជាដើម**

(1) មុខវិជ្ជាប្រលង: មាន2មុខវិជ្ជា គឺប្រលងទ្រឹស្តីនិងប្រលងអនុវត្ត

(2) រយៈពេលប្រលង: 70នាទី

(3) ជម្រើសចម្លើយ: 3ជម្រើស

(4) ភា សា: ភាសាជប៉ុន (មានដាក់របៀបអានពីលើអក្សរកាន់ជិ)

(5) វិធីសាស្ត្រអនុវត្ត: ការប្រលង តាម ប្រព័ន្ធកុំព្យូទ័រ (ទម្រង់ CBT)

សំណួរត្រូវបានបង្ហាញដោយប្រើកុំព្យូទ័រដែលមាននៅមណ្ឌលប្រលង។
បេក្ខជនប្រលង ត្រូវមើលសំណួរដែលបង្ហាញនៅលើអេក្រង់
ហើយឆ្លើយនៅលើអេក្រង់កុំព្យូទ័រតែម្តង។

(6) ចំនួនសំណួរ ការបែងចែកពិន្ទុ:

| ចំណុច | ប្រលងទ្រឹស្តី | | ប្រលងអនុវត្ត | |
|---|---|---|---|---|
| | ចំនួនសំណួរ | ការបែងចែកពិន្ទុ | ចំនួនសំណួរ | ការបែងចែកពិន្ទុ |
| ចំណេះដឹងទូទៅអំពីអនាម័យចំណីអាហារ | 25សំណួរ | ពិន្ទុពេញ75ពិន្ទុ (1សំណួរ 3ពិន្ទុ) | ការប្រលងវាយតម្លៃ 4សំណួរ ការបង្កើតផែនការ 2សំណួរ | ពិន្ទុពេញ 30ពិន្ទុ (1សំណួរ 5ពិន្ទុ) |
| កត្តាគ្រោះថ្នាក់ | | | | |
| ការគ្រប់គ្រងអនាម័យទូទៅ | | | | |
| ការគ្រប់គ្រងអនាម័យដោយ HACCPP | | | | |
| សុវត្ថិភាពការងារ | 5សំណួរ | ពិន្ទុពេញ 25ពិន្ទុ (1សំណួរ 5ពិន្ទុ) | ការប្រលងវាយតម្លៃ 4សំណួរ | ពិន្ទុពេញ 20ពិន្ទុ (1សំណួរ 5ពិន្ទុ) |
| | 30សំណួរ | 100ពិន្ទុ | 10សំណួរ | 50ពិន្ទុ |

[ឯកសារជំនួយ]
សូមអានចំណុចឆ្លើយតបនិមួយៗនៅជំពូក1ដល់ជំពូក3នៃសៀវភៅសិក្សា។

## 4. ស្តង់ដារជាប់

ការជាប់គឺត្រូវបានពិន្ទុចាប់ពី98ពិន្ទុឡើងទៅក្នុងពិន្ទុពេញ150ពិន្ទុ (អត្រាចម្លើយត្រូវ65%ឡើងទៅ)។

## 5. តម្លៃប្រលង

8000យ៉េន (រួមទាំងពន្ធ)
ថ្លៃប្រលងដែលបានបង់រួចមិនអាចសងត្រឡប់វិញបានទេ។
ប៉ុន្តែ ក្នុងករណីបន្ទាប់ថ្លៃប្រលងនឹងត្រូវបានសងត្រឡប់វិញ។
・នៅពេលការប្រលងមិនអាចប្រព្រឹត្តទៅបានដោយសារបញ្ហាខាង OTAFF
・នៅពេលដែលខាង OTAFFបានសម្រេចថាការប្រលងមិនអាចប្រព្រឹត្តទៅបានដោយសារតែគ្រោះធម្មជាតិជាដើម
※ក្នុងករណីអាចប្តូរទៅប្រលងថ្ងៃផ្សេងបាន ថ្លៃប្រលងមិនត្រូវបានសងត្រឡប់វិញទេ។

## 6. ការប្រលងម្តងទៀត

បន្ទាប់ពីប្រលងរួច ប្រសិនបើចង់ប្រលងក្នុងវិស័យដដែលម្តងទៀត អ្នកត្រូវទុកចន្លោះរយៈពេល 45ថ្ងៃដោយគិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃប្រលងលើកមុន។ មានន័យថា រាប់ពីថ្ងៃបន្ទាប់នៃថ្ងៃប្រលង ចាប់ពី46ថ្ងៃទៅទើបអាចប្រលងទៀតបាន។

## 7. ចំណុចប្រុងប្រយ័ត្នក្នុងថ្ងៃប្រលង

(1) ការប្រុងប្រយ័ត្ននៅកន្លែងចុះឈ្មោះ
1) រហូតដល់ថ្ងៃប្រលង សូមពិនិត្យមើល "ការប្រុងប្រយ័ត្នក្នុងថ្ងៃប្រលង" ជាដាច់ខាត។
2) ប្រសិនបើមិនបានយកសម្ភារៈដែលត្រូវយកមកនៅថ្ងៃប្រលងទេនោះអ្នកនឹងមិនត្រូវបានអនុញ្ញាតឱ្យចូលរួមប្រលងឡើយ។

(2) ការប្រុងប្រយ័ត្នមុនពេលចូលបន្ទប់ប្រលង

1) មុនពេលចូលបន្ទប់ប្រលងនឹងធ្វើការថតរូបផ្ទៃមុខ។រូបថតផ្ទៃមុខនឹងត្រូវយកទៅប្រើប្រាស់នៅលើលិខិតជូនដំណឹងលទ្ធផលប្រលង។

2) ក្នុងបន្ទប់ប្រលងមិនអនុញ្ញាតឱ្យយកសម្ភារៈអ្វីផ្សេងចូលក្រៅពីឯកសារបញ្ជាក់អត្តសញ្ញាណឡើយ។ សូមទុកសម្ភារៈទាំងអស់ រួមមានទូរស័ព្ទដៃ ឧបករណ៍សរសេរ នាឡិកាដៃ និងម៉ាស៊ីនគិតលេខទៅក្នុងទូដាក់អីវ៉ាន់លើកលែងតែឯកសារបញ្ជាក់អត្តសញ្ញាណតែប៉ុណ្ណោះ។

3) យើងនឹងធ្វើការត្រួតពិនិត្យសន្តិសុខដើម្បីមើលថាតើមានបំណងយកទូរស័ព្ទដៃជាដើមចូលដែរឬទេ។ សូមធ្វើតាមការណែនាំរបស់បុគ្គលិក។

4) ប្រសិនបើដឹងថាអ្នកមានបំណងយកទូរស័ព្ទដៃជាដើមចូលនោះអ្នកនឹងមិនអាចទទួលការប្រលងបានឡើយ។ សូមធ្វើតាមការណែនាំរបស់បុគ្គលិក។

5) ដើម្បីការពារបញ្ហាផ្សេងៗកន្លែងចុះឈ្មោះនិងទូដាក់អីវ៉ាន់ត្រូវបានតាមដានដោយប្រព័ន្ធកាមេរ៉ា។

(3) ចំណុចប្រុងប្រយ័ត្នពេលប្រលង

1) នៅក្នុងការប្រលង អ្នកនឹងប្រើម៉ៅស៍កុំព្យូទ័រ ដើម្បីឆ្លើយសំណួរ។ នៅពេលចុចប៊ូតុងប្រតិបត្តិ (Action Button) នៅលើអេក្រង់កុំព្យូទ័រ សូមផ្លាស់ទីម៉ៅស៍ដើម្បីនាំព្រួញលើអេក្រង់ទៅកាន់ប៊ូតុង ហើយចុចប៊ូតុងខាងឆ្វេងនៃម៉ៅស៍1ដង។ សូមចុចប៊ូតុងម៉ៅស៍តែម្តងប៉ុណ្ណោះ សូមកុំចុចលើសពី2ដង។

2) មុនប្រលង និងក្នុងអំឡុងពេលប្រលង ប្រសិនបើមានសរសេរអក្សរ ឬលេខលើរាងកាយ ឬលើសម្លៀកបំពាក់ជាដើម នឹងត្រូវបានចាត់ទុកថាជាការលួចចម្លង ហើយអាចត្រូវបានប្រាប់ឲ្យចេញពីបន្ទប់ប្រលង និងមិនអាចទទួលការប្រលងឡើយ។ សូមកុំសរសេរអក្សរ ឬលេខលើរាងកាយ ឬសម្លៀកបំពាក់ជាដើម។

3) ក្នុងអំឡុងពេលប្រលងមិនអាចឆ្លើយសំណួរណាមួយដែលពាក់ព័ន្ធនឹងរបៀបនៃការប្រលងឬខ្លឹមសារនៃការប្រលងឡើយ។ប្រសិនបើមានអ្វីមិនយល់ឬនៅពេលកុំព្យូទ័រមានបញ្ហាសូមលើកដៃភ្លាមៗ (ឬចុចប៊ូតុងហៅ) ដើម្បីហៅបុគ្គលិក។ក្រោយពេលបញ្ចប់ការប្រលង ទោះបីជាប្រាប់អោយដឹងក៏ដោយក៏មិនអាចដោះស្រាយបានដែរ។

4) អ្នកដែលបានដោះស្រាយសំណួរចប់លឿន អាចចេញពីបន្ទប់ប្រលងបាន។

5) យើងនឹងចែកក្រដាសសម្រាប់កត់ត្រា និងឧបករណ៍សរសេរ (ឬថេប្លេតអេឡិចត្រូនិច) ដែលអាចប្រើបានក្នុងបន្ទប់ប្រលង។ម្យ៉ាងទៀតអាចប្រើម៉ាស៊ីនគិតលេខដែលមាននៅលើកុំព្យូទ័របានផងដែរ។

6) ក្នុងអំឡុងពេលប្រលង សូមកុំធ្វើសកម្មភាពមិនត្រឹមត្រូវណាមួយឱ្យសោះ។ ដើម្បីបង្ការសកម្មភាពមិនត្រឹមត្រូវ គឺត្រូវដានតាមដោយប្រព័ន្ធកាមេរ៉ា។ បុគ្គលិកនឹងដើរត្រួតពិនិត្យនៅក្នុងបន្ទប់ប្រលង។
7) ប្រសិនបើបានធ្វើសកម្មភាពមិនត្រឹមត្រូវ ការប្រលងនឹងត្រូវបានផ្អាកភ្លាមៗ ហើយអ្នកនឹងត្រូវចេញពីទីកន្លែង។

(4) ការប្រុងប្រយ័ត្នពេលចេញពីបន្ទប់ប្រលង បន្ទាប់ពីបញ្ចប់ការប្រលង

1) បន្ទាប់ពីប្រលងចប់ ត្រូវចេញពីបន្ទប់ប្រលង។
2) យកសម្ភារៈដែលបានដាក់ក្នុងទូអីវ៉ាន់ចេញ។
3) ដាច់ខាតសូមប្រគល់កូនសោទូអីវ៉ាន់អោយទៅកន្លែងចុះឈ្មោះវិញ។ប្រសិនបើច្រឡំយកត្រឡប់ទៅផ្ទះ នោះអ្នកនឹងត្រូវតម្រូវឱ្យបង់ប្រាក់សម្រាប់ថ្លៃប្តូរសោទូអីវ៉ាន់ថ្មី

(5) ការប្រុងប្រយ័ត្នផ្សេងទៀត

1) ក្នុងករណីដែលមានសកម្មភាពរំខាន បង្កផលប៉ះពាល់ឬមានបំណងបង្កផលប៉ះពាល់ដល់បេក្ខជនដទៃ ឬបុគ្គលិក អ្នកនឹងមិនអាចទទួលការប្រលងទៀតបានទេ។
2) នៅក្នុងកន្លែងប្រលង (រួមទាំងកន្លែងចុះឈ្មោះ) មិនអាចថតរូប ឬថតវីដេអូជាដើម ឬថតសំឡេងបានទេ។
3) នៅពេលជក់បារី សូមជក់នៅកន្លែងដែលត្រូវបានកំណត់។
4) ក្នុងបន្ទប់ប្រលង មានតែបេក្ខជនប្រលងតែប៉ុណ្ណោះដែលអាចចូលបាន។ (អ្នកដែលមកជាមួយមិនអាចចូលបានទេ។)
5) បុគ្គលិកមិនអាចឆ្លើយសំណួរណាមួយទាក់ទងនឹងលទ្ធផលប្រលង ឬពិន្ទុបានឡើយ។

## 8. ការហាមឃាត់សកម្មភាពមិនត្រឹមត្រូវនិងការលុបចោលលទ្ធផលពិន្ទុនៃការប្រលងជាប់ជាដើម

(1) សកម្មភាពមិនត្រឹមត្រូវ គឺជាសកម្មភាពដូចតទៅនេះ។

1) សកម្មភាពទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់ការផ្តល់ឱកាសប្រលងដោយស្មើភាពដែលរៀបចំដោយអង្គភាព រួមមានការចុះឈ្មោះក្លែងបន្លំក្នុង My Page ការចុះឈ្មោះប្រលងស្ទួនឬសកម្មភាពណាដែលប្រើប្រាស់មធ្យោបាយមិនត្រឹមត្រូវដើម្បីបានទទួលការប្រលង ឬមានបំណងចង់ប្រលង
2) សកម្មភាពទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់ការវាស់ស្ទង់សមត្ថភាពរបស់បេក្ខជនប្រលងឱ្យបានត្រឹមត្រូវនិងយុត្តិធម៌ដែលរៀបចំដោយអង្គភាពព្រមទាំងសកម្មភាពដែលរារាំងដល់ការអនុវត្តការប្រលងឱ្យបានត្រឹមត្រូវផងដែរ
3) សកម្មភាពទាំងឡាយណាដែលប៉ះពាល់ដល់ការរក្សាការសម្ងាត់នៃវិញ្ញាសាប្រលងរួមមាន

ការទាមទារសុំព័ត៌មានពីបុគ្គលិកដែលពាក់ព័ន្ធក្នុងការប្រលងអំពីព័ត៌មានសម្ងាត់ដូចជាវិញ្ញាសាប្រលងជាដើម

1) ការកែបន្លំធ្វើលិខិតជូនដំណឹងលទ្ធផលប្រលង
2) ក្រៅពីនេះរាល់សកម្មភាពទាំងឡាយណាដែលរារាំងដល់ការអនុវត្តការប្រលងឱ្យបានត្រឹមត្រូវ យុត្តិធម៌ និងស្មើភាព

(2) សកម្មភាពដូចខាងក្រោមនេះនៅក្នុងបន្ទប់ប្រលងនឹងត្រូវចាត់ទុកថាជាសកម្មភាពមិនត្រឹមត្រូវ ហើយការប្រលងនឹងត្រូវបានបញ្ឈប់ភ្លាមៗ ក្នុងដំណាក់កាលដែលបានរកឃើញ។

1) បុគ្គលផ្សេងក្រៅពីបេក្ខជនប្រលង កំពុងទទួលការប្រលង
2) សកម្មភាពលួចចម្លងដូចជាការនិយាយគ្នានិងការលួចមើលអេក្រង់របស់បេក្ខជនដទៃជាដើម នៅក្នុងបន្ទប់ប្រលង
3) ការនាំយកព័ត៌មានចូលក្នុងបន្ទប់ប្រលង ការនាំយកព័ត៌មានចេញពីបន្ទប់ប្រលង ឬសកម្មភាពណាមួយដែលចូលក្នុងករណីទាំងនេះ
4) ការនាំចូលនិងការប្រើប្រាស់រាល់សម្ភារៈផ្ទាល់ខ្លួនក្រៅពីសម្ភារៈដែលត្រូវបានអនុញ្ញាត ឬសកម្មភាពដែលចូលក្នុងករណីនេះ (※)
5) ការសរសេរនៅលើរបស់របរផ្សេងៗ ក្រៅពីក្រដាសព្រាង ឬថេបប្លេតអេឡិចត្រូនិចដែលមណ្ឌលប្រលងបានផ្តល់ឱ្យនិងការចូលក្នុងបន្ទប់ប្រលងដោយសភាពមានសរសេរនៅលើរាងកាយ (※)

※មិនថាព័ត៌មានដែលបាននាំចូលនាំចេញឬការសរសេរនោះពាក់ព័ន្ធឬមិនពាក់ព័ន្ធនឹងការប្រលងក៏ដោយក៏ត្រូវចាត់ទុកថាជាសកម្មភាពមិនត្រឹមត្រូវដែរ។

(3) របៀបដោះស្រាយក្នុងករណីមានសកម្មភាព មិនត្រឹមត្រូវ

1) ក្នុងករណីដែលបានប្រលងឬមានបំណងចង់ចូលប្រលងតាមមធ្យោបាយមិនត្រឹមត្រូវនោះនឹងមិនត្រូវបានកែដាក់ពិន្ទុឡើយ។
2) ទោះបីជាបេក្ខជនប្រលងជួបបញ្ហានៅពេលក្រោយដោយសារតែបានប្រព្រឹត្តសកម្មភាពមិនត្រឹមត្រូវក៏ដោយ ក៏អង្គភាព OTAFF មិនទទួលខុសត្រូវ ឬមានកាតព្វកិច្ចជាដើមនោះទេ។ ហើយក៏មិនសងថ្លៃប្រលងត្រឡប់មកវិញដែរ។
3) ក្នុងករណីដែលមានការសរសេរនៅលើរាងកាយឬនៅលើសម្ភារៈផ្សេងៗអង្គភាពនឹងធ្វើការកត់ត្រាទុកនូវវត្ថុតាងទាំងនោះ (រួមទាំងការថតរូប) ផងដែរ។
4) ក្នុងករណីដែលដឹងថាអ្នកប្រព្រឹត្តសកម្មភាពមិនត្រឹមត្រូវក្រោយពេលលិខិតជូនដំណឹងលទ្ធផលប្រលងត្រូវបានចេញរួចរាល់ហើយនោះ  លទ្ធផលពិន្ទុនៃការប្រលងជាប់ជាដើម

នឹងត្រូវលុបចោលវិញ។ការលុបចោលលទ្ធផលនៃពិន្ទុប្រលងជាប់នឹងត្រូវរាយការណ៍ជូនទៅភ្នាក់ងារអន្តោប្រវេសន៍តាមរយៈក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ យើងនឹងជូនដំណឹងអំពីការលុបចោលលទ្ធផលនៃពិន្ទុប្រលងជាប់ទៅកាន់បុគ្គលនោះព្រមទាំងលុបចោលទិន្នន័យលិខិតជូនដំណឹងលទ្ធផលប្រលងដែលបានបង្ហោះក្នុង My Page ផងដែរ។

5) ក្នុងករណីដែលបានប្រព្រឹត្តសកម្មភាពមិនត្រឹមត្រូវ អាចនឹងមិនឱ្យទទួលការប្រលងរហូតដល់រយៈពេលអតិបរមា 5 ឆ្នាំ។